**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ២៧៩៦ ព.ណ.ក.ណ.ស

ថ្ងៃសុក្រ ៥កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ២០២២

**ជម្រាបមក**

**លោក/លោកស្រីប្រធានក្រុមហ៊ុន ស៊ាង យី ប៊ីនឡាង ត្រេឌីង ឯ.ក**

**កម្មវត្ថុ:** ការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលគ្រាប់ពូជរុក្ខជាតិ ខ្យាច់ក្រអូប(ទុកដាក់សំរាម) សម្រាប់សត្វចិញ្ចឹម បន្លែស្រស់ ផ្លែឈើស្រស់ សត្វរស់ ដើមឈើរស់ គ្រាប់ធញ្ញជាតិដែលមិនទាន់កែច្នៃ និងផលិតផលកែច្នៃ គ្រាប់បន្លែដែលអាចរក្សាទុក អាហារដែលមានមូលដ្ឋានពីសាច់ ត្រី ផ្លែឈើ ចាហួយ ស៊ុត ផ្លែឈើគ្រីស្តាល់ និងតៅហ៊ូម៉ាក KOUWEIWANG 口味王 របស់ក្រុមហ៊ុន **ស៊ាង យី ប៊ីនឡាង ត្រេឌីង ឯ.ក** ក្នុងព្រះរាជាណាចក្រកម្ពុជា។

**យោង:**
- មាត្រា ៣ និងមាត្រា ១១នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតស្នើសុំរបស់ក្រុមហ៊ុន **ស៊ាង យី ប៊ីនឡាង ត្រេឌីង ឯ.ក** ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០២២
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន HUNAN KOUWEIWANG GROUP CO., LTD. ចុះថ្ងៃទី ០១ ខែមិថុនា ឆ្នាំ ២០២២
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី M/១៤៧៥៩៤៣/២០ ជំពូក ២៩ និង ៣១ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០២០។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលគ្រាប់ពូជរុក្ខជាតិ ខ្សាច់ក្រអូប(ទុកដាក់សំរាម) សម្រាប់សត្វចិញ្ចឹម បន្លែស្រស់ ផ្លែឈើស្រស់ សត្វរស់ ដើមឈើរស់ គ្រាប់ធញ្ញជាតិដែលមិនទាន់កែច្នៃ និងផលិតផល កែច្នៃ គ្រាប់បន្លែដែលអាចរក្សាទុក អាហារដែលមានមូលដ្ឋានពីសាច់ ត្រី ផ្លែឈើ ចាហួយ ស៊ុត ផ្លែឈើគ្រីស្តាល់ និងតៅហ៊ូពាក់ម៉ាកខាងលើ របស់ក្រុមហ៊ុន **ស៊ាង យី ប៊ីនឡាង ត្រេឌីង ឯ.ក** ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលទទួលបានពីក្រុមហ៊ុន HUNAN KOUWEIWANG GROUP CO., LTD. ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខដែលក្រសួងបានតម្កល់ទុករួចហើយ។

លិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខនេះមានសុពលភាពត្រឹមថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០២៣ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិមុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន HUNAN KOUWEIWANG GROUP CO., LTD. ដែលជាម្ចាស់ម៉ាក។

ចាប់ពីក្រោយរយៈពេល ៩០(កៅសិប)ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខនេះអ្នកទទួលសិទ្ធិស្របច្បាប់មានសិទ្ធិប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការរារាំងទំនិញដែលនាំចូលស្របគ្នា។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវផ្សព្វផ្សាយលិខិតខាងលើនេះជាបន្ទាន់ក្នុងទំព័រខាងមុខរបស់សារព័ត៌មានក្នុងព្រះរាជាណាចក្រកម្ពុជា និងបណ្តាញសង្គមនានា និងត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

**ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**អ៊ឹក-ប្រជា**

*__ចម្លងជូន:__*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ** នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្តេចក្រឡាហោម **ស ខេង***
- *ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *ខុទ្ទកាល័យ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (ក.ប.ប)*
- *អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*
- *អគ្គនាយកដ្ឋានពន្ធដារ*
- *ឯកសារ- កាលប្បវត្តិ*